Available languages 한국어 English 中文 Français 日本語

អាជ្ញាធរអប្សរា
APSARA

ក្រមប្រតិបត្តិអង្គរ

អង្គរសូមស្វាគមន៍!

ឧទ្យានអង្គរជាអតីតរាជធានីចក្រភពខ្មែរចាប់ពីសតវត្សទី៩ ដល់សតវត្សទី១៥ និងជារាជធានីមួយធំជាងគេនៅលើពិភពលោកនៅសតវត្សទី១២។ បច្ចុប្បន្ននេះ ឧទ្យានអង្គរនៅតែជាបូជនីយដ្ឋានសម្រាប់ពុទ្ធសាសនិកនិងប្រជាពលរដ្ឋ ដែលតែងមកគោរពបូជាសំពះបន់ស្រន់ជារៀងរាល់ថ្ងៃ ហើយជាទីលំនៅឋានរបស់ប្រជាពលរដ្ឋប្រមាណ ១៣០ ០០០នាក់ផងដែរ។

អាជ្ញាធរជាតិអប្សរាគឺជាស្ថាប័នទទួលខុសត្រូវក្នុងការអភិរក្សនិងអភិវឌ្ឍឧទ្យានអង្គរ ចាប់តាំងពីឆ្នាំ១៩៩៥មក។ គោលដៅមួយក្នុងចំណោមគោលដៅទាំងឡាយរបស់យើងគឺធ្វើយ៉ាងណាឱ្យធានាបាននូវសុវត្ថិភាពរបស់ភ្ញៀវ បទពិសោធន៍ទស្សនា និងការគោរពដល់សហគមន៍របស់យើង។ ក្រមប្រតិបត្តិអង្គរនេះត្រូវបានតាក់តែងឡើងដោយមានការសហការជាមួយអ្នកស្រុកអង្គរ ភ្ញៀវទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ និងក្រុមការងារជួសជុលប្រាសាទ។

ដើម្បីរួមចំណែកជួយអភិរក្សឧទ្យានអង្គរសម្រាប់មនុស្សជំនាន់ក្រោយ និងធ្វើឱ្យបទពិសោធន៍ទស្សនារបស់លោកអ្នកកាន់តែប្រសើរ សូមមេត្តាគោរពតាមក្រមប្រតិបត្តិអង្គរដូចខាងក្រោម៖

ទីសក្ការៈបូជា



ឥរិយាបថផ្ទុយពីវប្បធម៌ខ្មែរ ការនិយាយខ្លាំងៗ សកម្មភាពឡូឡា គឺជាសកម្មភាពមិនសមរម្យចំពោះតំបន់អង្គរ ហើយអាចរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរដទៃទៀត។ សូមមេត្តាទស្សនាដោយភាពស្ងប់ស្ងាត់ និងគោរពភ្ញៀវដទៃ។

ទីតាំងហាមឃាត់



ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោកអ្នក និងដើម្បីអភិរក្សតំបន់អង្គរ សូមមេត្តាគោរពស្លាកសញ្ញានៅតាមប្រាសាទ។ សូមប្រយ័ត្ននៅពេលទស្សនា និងហាមឡើងលើគំនរថ្ម។

ការពិសាថ្នាំរីនិងការចោលសំរាម



ក្នុងនាមជាសមាជិកអង្គការសុខភាពពិភពលោក ឧទ្យានអង្គរគឺជារមណីយដ្ឋានគ្មានផ្សែងបារីតាំងពីឆ្នាំ២០១២។ ការពិសាបារីអាចរំខានដល់អ្នកដទៃនិងអាចបណ្តាលឱ្យមានអគ្គិភ័យ។ ដើម្បីចូលរួមការពារបរិស្ថានសូមមេត្តាកុំជក់បារី និងចោលសំរាម។

សំលៀកបំពាក់



អាវវាលក្លៀក ចំហដើមទ្រូង ខោនិងសំពត់ខ្លីលើជង្គង់សុទ្ធតែជាសម្លៀកបំពាក់ ដែលមិនសមរម្យនៅក្នុងវប្បធម៌ខ្មែរ និងត្រូវហាមឃាត់ជាច់ខាតនៅតាមទីសក្ការៈ។ ត្រូវស្លៀកពាក់សមរម្យនៅគ្រប់ទីកន្លែងក្នុងឧទ្យានអង្គរ។

ការឱ្យស្ករគ្រាប់ឬថវិកាដល់កុមារ



ការទិញរបស់របរ ការឱ្យស្ករគ្រាប់ឬថវិកាដល់កុមារអាចជំរុញឱ្យកុមារមិនទៅសាលារៀន ហើយជំរុញឱ្យពួកគេមានទំលាប់សុំទាន។ បើចង់ជួយកុមារ សូមផ្តល់អំណោយដល់អង្គការមនុស្សធម៌ដែលគេទទួលស្គាល់ថាជាអង្គការល្អ។

ប្រាង្គប្រាសាទ



ការប៉ះរូបចម្លាក់ ការអង្គុយលើកន្លែងដែលមានសភាពទ្រុឌទ្រោម ការផ្អែកលើសំណង់ប្រាសាទ ការផ្លាស់ប្តូរទីតាំងឬយកថ្មបុរាណ និងការគូសវាសលើថ្មជាដើមត្រូវបានហាមឃាត់ជាច់ខាត។ កាបូបស្ពាយក្រោយខ្នង ឆត្រមានដងមុតស្រួចជើងទ្រម៉ាស៊ីនថត និងស្បែកជើងកែងខ្ពស់មិនគួរយកឬពាក់ចូលក្នុងប្រាសាទឡើយ។

ព្រះសង្ឃ



នៅប្រទេសកម្ពុជា ព្រះសង្ឃជាបុគ្គលសក្ការៈ។ ប្រសិនបើលោកអ្នកចង់ថតរូប សូមមេត្តាសុំការអនុញ្ញាតពីព្រះសង្ឃជាមុនសិន។ ស្ត្រីមិនត្រូវប៉ះ ឈរ ឬអង្គុយកៀកព្រះសង្ឃឡើយ។

⚠ រាល់ការលួច ការធ្វើឱ្យបាក់បែកឬខូចខាតថ្មប្រាសាទ ក៏ដូចជាសកម្មភាពអាសអាភាសនិងអាក្រាតកាយនៅទីសាធារណៈជាអំពើល្មើសច្បាប់។

សហការដោយ : UNESCO UNWTO AFFILIATE MEMBER

សូមផ្តល់យោបល់របស់លោកអ្នក តាមរយៈគេហទំព័រ ឬ QR code នេះ។ សូមអរគុណ!
www.apsaraauthority.gov.kh/survey

ការបង្ហោះ Drone ការថតរូបភាពសន្លឹកឬវីដេអូដើម្បីធ្វើអាជីវកម្មត្រូវសុំការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរាជាមុនសិន។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ:www.apsaraauthority.gov.kh

គាំទ្រដោយ : SOKHA Angkor RESORT & SPA SIEM REAP CAMBODIA AIRPORTS

APSARA © 2015